«ចន្ទា?»

បងខ្ញុំស្រែកពីរម៉ាត់ខ្លីធ្វើឱ្យចិត្តខ្ញុំស្លុតដូចគេមកកន្ត្រាក់។

ខ្ញុំរបូតសៀវភៅពីដៃងាកទៅឃើញបងឌីដើរវែងៗមកទាំងត្រហេបត្រហបៈ

«ចន្ទា! ឆ្អឹងខ្មោចទាំងអស់!»

ខ្ញុំបើកភ្នែកសស្លើតសម្លឹងបងឌីន រួចក្រឡេកទៅរកមនុស្សម្នាដែលកំពុងចោមរោមពាង។

បេះដូងខ្ញុំដាច់ជាកំណាត់ៗនឹកឃើញតែនារីក្នុងសុបិន។

«នាងត្រូវគេសម្លាប់ចោល ហើយញាត់ទុករាប់រយឆ្នាំក្នុងបរិវេណដីនេះ? សូម្បីកំណត់ហេតុចុងក្រោយរបស់នាង ក៏ពួកគេបោះក្រោមបាតពាង ព្រោះតែមិនចេះអានវា?»

ខ្ញុំគិតតែម្នាក់ឯង។

បងឌីនបាននិយាយម្តងទៀតថាៈ

«ឆ្អឹងខ្មោចទាំងអស់!»

«មិនមែនតែម្នាក់ទេ?»

ខ្ញុំភ្លាត់មាត់សួរ។

បងឌីនគ្រវីក្បាលស្ទើរដាច់ ហើយខ្សឹបដាក់ត្រចៀកប្អូនដែលកំពុងភាំងៈ

«ច្រើនគ្នាណាស់ ម៉េចក៏ប្អូនប្រាំនាក់ដែរ!»

ពាក្យចចាមអារ៉ាមជាច្រើនត្រូវបានគេនិយាយរហូតមកដល់ល្ងាច។

អាជ្ញាធរភូមិឃុំបានចុះមកមើលអដ្ឋិធាតុ ហើយនិងសួរនាំពីទីតាំងដែលយើងបានរកឃើញ។ ខ្ញុំប្រគល់សៀវភៅទៅឱ្យពួកគេ បន្ទាប់ពីបានស្លុងខ្លួនលែងនឹកឃើញរឿងបាយទឹក។

នារីនោះចង់ឱ្យខ្ញុំជួយដោះលែងពួកគេ ហើយធ្វើបុណ្យទៅអនាគតជាតិឬអ្វី?

ចុះហេតុអ្វីជាខ្ញុំ?

មិនយូរប៉ុន្មាន អ្នកភូមិរកបានបុរសចំណាស់ម្នាក់។

ខ្ញុំមិនដឹង ហើយក៏មិនខ្វល់ថាគាត់មកពីណាដែរ ដែលសំខាន់គឺអ៊ំគង់មកខ្សឹបនឹងខ្ញុំថា បុរសចំណាស់សឹងតែ ៨០ ប្លាយនោះ ឈ្មោះទៀង។

តាទៀងនេះអះអាងថា ពុកគាត់ធ្លាប់ប្រាប់រឿងតំណាលតៗគ្នាមួយកាលពីឆ្នាំ ១៨៨០ ជាងដែលមានគ្រួសារគហបតីម្នាក់ត្រូវបានបាត់ខ្លួនមួយគ្រួសារ។

«ដោយសារតែកូនក្រមុំរបស់គាត់បានសម្លាប់ខ្លួនគេចវេះមង្គលការ ហើយគ្រួសារខាងប្រុសជាអ្នកមានអំណាច តានោះដោយជឿសម្ដីអុជអាលរបស់ប្រពន្ធក្រោយ គាត់ទ្រាំការអាម៉ាស់មិនបាន ក៏ចាប់អ្នកជំនិតកូនគាត់ទាំងអស់ដែលជាទាសករ ទៅធ្វើទុក្ខបុកម្នេញដល់ស្លាប់ ហើយកប់ទៅជាមួយគ្នា! ក្រោយមក រាជការស៊ើបដឹងពីរឿងទោសគ្រួសារដ៏សាហាវឃោរឃៅនេះ ក៏ស្វែងរកយកមកសួរនាំរកត្រូវខុស តែពួកគេបានគេចខ្លួនបាត់ដំណឹងមកទល់ពេលនេះ!»

ខ្ញុំស្លុតអារម្មណ៍ភ្នែកសម្លឹងពាងដែលអ្នករាជការកំពុងពិនិត្យ។ មនុស្សមកកាន់តែច្រើនឡើងៗភាគច្រើនជាចាស់ព្រឹទ្ធាចារ្យ និងព្រះសង្ឃ។ ខ្ញុំថយទៅម្ខាងរង់ចាំមើលការដោះស្រាយទាំងចិត្តពិបាកសែនពិបាក។

ហើយយប់នោះ ចាស់ៗបានយល់ស្របគ្នាថានឹងធ្វើបុណ្យបញ្ជូនកុសលឱ្យអដ្ឋិធាតុក្នុងពាងនោះតាមវិធីដែលបានព្រមព្រៀងរវាងចាស់ៗអ្នកចេះដឹងរឿងអស់នេះ។

ប្រហែលជាបងឌីនជាអ្នករាយការណ៍ ម៉ែបានទូរសព្ទមកបណ្ដាក់គ្នាជាមួយពុកឱ្យខ្ញុំវិលទៅស្រុកវិញឈប់តាមដាន ឬរស់នៅកន្លែងនេះ ប៉ុន្តែបំណាច់ចិត្តចង់ដឹងឱ្យបានចប់ចុងដើម ខ្ញុំក៏នៅមើលគេ។

បន្ទាប់ពីព្រះសង្ឃបានធ្វើពិធីតាមសាសនារួចហើយ ធាតុត្រូវបានយកទៅបញ្ចុះនៅវត្តមួយក្នុងភូមិតាមប្រពៃណី។

នៅពេលដែលមន្ត្រីចេញអស់ ដល់វេនខាងលោកតាអាចារ្យធ្វើពិធីសុំសេចក្ដីសុខតាមរបៀបរបស់គាត់។

ក្នុងបរិយាកាសស្ងាត់វិញ អ៊ំស្រីភរិយាអ៊ំគង់បានមកអង្គុយនិយាយប្រាប់គ្រួសារខ្ញុំថា៖

«អ្វីៗបានយកចេញអស់ហើយ អាចារ្យក៏ត្រៀមនឹងធ្វើពិធីរបស់គាត់ សុំសុខសប្បាយសាជាថ្មីឡើងវិញ!»

អ៊ំទាំងពីរហៅពួកខ្ញុំឱ្យរើទៅស្នាក់នៅផ្ទះគាត់សិនក៏បាន ប៉ុន្តែពួកខ្ញុំសម្រេចចិត្តថាស្នាក់នៅផ្ទះសំណាក់សិនល្អជាង។

តាមស្ដាប់មន្ត្រីខ្លះដែលមកចូលរួម អះអាងថា សង្ស្វាររបស់នារីរងគ្រោះដែលគេយល់ថាបានធ្វើទំព ក៏បានមានជំងឺស្លាប់ ដោយមុនពេលស្លាប់សុំឱ្យគ្រួសារបញ្ជូនធាតុឱ្យមកកប់រួមជាមួយនាងជាសង្សារដែរ។

ទោះយ៉ាងណា បងឌីនលូកមាត់មកជំទាស់តិចៗ៖

«ពាក្យអ្នកនិយាយទាំងអស់ហ្នឹងមិនទំនងច្រើនចំណុចណាស់! ពាងតូចប៉ុណ្ណឹង តើដាក់មនុស្សស្លាប់បានប៉ុន្មាននាក់? ឬមួយគេកប់ចោល ហើយចុងក្រោយគាស់មកបង្ខាំងទុករួមគ្នានៅនេះ? អ្នូយវិលមុខ?»

គ្មានអ្នកណាបកស្រាយចម្ងល់នេះទេ។ ហើយខ្ញុំក៏មិនចង់ដឹងអ្វីវែងឆ្ងាយទៀតដែរ។

នាងមកពន្យល់សប្តិខ្ញុំ គឺចង់ឱ្យមានពិធីបុណ្យមួយឧទ្ទិសរំដោះនាង ពេលនេះគ្រប់យ៉ាងជិតបានសម្រេចហើយ។

យប់នោះ ពេលគេងស្នាក់នៅផ្ទះសំណាក់ ខ្ញុំបានធ្វើការសម្រេចចិត្តរួមជាមួយភរិយាថា វិលទៅរកការងារនៅភ្នំពេញវិញ។ ចិត្តខ្ញុំលែងស្នាក់នៅទីនេះទៀតហើយ កុំថាឡើយដីដែលក្រុមហ៊ុនជួលមានបញ្ហាច្រើន អារម្មណ៍ទាំងមូលនៅតែមិនកក់ក្តៅក្នុងការរស់នៅទីនេះឆ្ងាយញាតិមិត្ត។

ព្រឹកឡើង ខ្ញុំបកទៅរៀបចំអីវ៉ាន់ជាមួយបងឌីន ក៏ឃើញមេភូមិនាំម្ចាស់ដីមកដល់។

គាត់ឈ្មោះថាមីងសារុំ អាយុប្រហែល ៥០ ប្លាយ។ លោកតាអាចារ្យកាលពីម្សិល ក៏មកដែរ ដោយនាំចាស់ៗប្លែកមុខពីរបីនាក់មកជាមួយ។ ពួកគាត់ស្លៀកពាក់របៀបជាអ្នកស្នាក់នៅបម្រើព្រះសង្ឃនៅវត្ត។

គេប្រាប់ខ្ញុំថា ម្ចាស់ដីប្រញាប់ធ្វើពិធីបណ្តេញឧបទ្រព។

បងឌីនតាមថាត្រូវទៅផ្ទះតាំងពីព្រឹក តែដល់មានរឿងច្រើន ម៉ែឱ្យគាត់បង្អង់ស្នាក់នៅបន្ត ត្រៀមឱ្យតែប្អូនសុំគេវិលទៅភ្នំពេញរួចរាល់ គាត់ជួយរៀបចំដឹកជញ្ជូន។

ខ្ញុំ និងបងឌីននៅសំងំចាំមើលរបៀបគេបន់ស្រន់នៅទីនេះ។

ថ្ងៃបន្តិច ខ្ញុំឃើញតាអាចារ្យបង្គាប់ឱ្យគ្នាគាត់ធ្វើផ្ទះឫស្សីតូចៗទំហំប្រហែលជាប៉ុនផ្ទះម្រេញគង្វាលចំនួន ៩ ដាក់គ្រឿងនានា រួមមានសំពត់សារុង គ្រឿងតុបតែង ប្រេងម្សៅ អង្ករ អំបិល។ ភ្លេងខ្មែរយើងមួយវង់បានមកដល់បន្ទាប់ពីនោះ។

ខ្ញុំចម្លែកចិត្តតាមដានមិនហ៊ានចន្លោះទេ។

បន្ទាប់មកក៏ធ្វើពន្លាកំណាត់សធំមួយប៉ុនក្រោលសេះ ហើយមានដាក់គ្រែឫស្សីមួយទទឹងប្រមាណជា ១ ម៉ែត្រ ២ តឹក និងបល្ល័ង្កឈើមួយត្រួតដោយកៅអីឫស្សីពីលើគ្រែនោះតែម្តងនៅកណ្តាលពន្លាកំណាត់។

ក្រោមជើងគ្រែកៅអី គេមានផ្ទុកនូវទូកធំមួយបណ្តោយប្រមាណជា ១ ម៉ែត្រ ៨ តឹក ទទឹងកន្លះម៉ែត្រ ពេញប្រៀបទៅដោយព័ស្តុភារ អាហារចំណីចំណុកក្រៀម និងភេសជ្ជៈ។

មីងសារុំគាត់ជាអ្នកចំណាយ និងដុតដៃជើងជាមួយចាស់ៗ។

ទោះយ៉ាងណា ពិធីទីនេះខុសពីអ្វីដែលខ្ញុំតែងឃើញ។ ខ្ញុំជាប់អារម្មណ៍ចង់ដឹងណាស់ ពេលដំបូងគេចាប់សង់ពន្លា ក៏មិនបានឃើញមានសែនព្រេនក្រុងពាលីអីច្រើនធំដុំទេ គ្រាន់តែមានចេកមួយស្និត និងធូបប៉ុន្មានសរសៃហុយៗ ហើយក៏ចាប់ផ្តើមធ្វើការ។ នៅលើផ្ទះ អ្នកភូមិ និងចាស់ៗនិយាយគ្នាជុំវិញការរៀបចំពិធី គឺនិយាយតែអំពីអ្វីដែលពួកគាត់ត្រូវការ មិនបានប្រាប់អំពីដំណើរដើមទងអ្វីច្រើនឡើយ ដូច្នេះខ្ញុំនៅតែចិញ្ចឹមចិត្តមិនអស់មិនហើយជានិច្ច។

រសៀលប្រមាណជាម៉ោង ១ ក្រុមភ្លេងខ្មែរមួយក្រុមមានគ្នា ៥ នាក់បានជិះឡានមកដល់ ហើយចូលក្នុងផ្ទះ។ ខ្ញុំកាន់តែនឹកឆ្ងល់ខ្លាំង ទើបសម្រេចចិត្តចូលទៅសួរម្ចាស់ដី។ ពេលនោះ មីងសារុំកំពុងរៀបចំផ្កាជាមួយគ្នាគាត់។

«មីងដូចជាចំណាយច្រើនណាស់នៀក! ខ្ញុំមិនដែលឃើញពិធីសែនអ្វីធំយ៉ាងនេះទេ មីង!»

មីងសារុំមិនមាត់អ្វីច្រើន គាត់ញញឹមតិចៗ ហើយប្រាប់ខ្ញុំវិញខ្សឹបៗ៖

«អត់អីទេ! កុំភ័យពេក! ចាំទំនេរដៃបន្តិច មីងនិយាយប្រាប់!»

ខ្ញុំឡើងមកផ្ទះចាប់អុជធូបថ្វាយគ្រូបាធ្យាយ និងជំនាងផ្ទះសុំសុខសប្បាយ។ ចិត្តខ្ញុំជឿជាក់ទាំងស្រុងលើការរៀបចំរបស់ម្ចាស់ដី និងតាៗ តែចិត្តមួយទៀត ខ្ញុំនៅមិនសុខមិនសាប់ទេ ព្រោះទោះខ្ញុំលែងនៅទីនេះ វាលែងមានអីពាក់ព័ន្ធនឹងខ្ញុំ ខ្ញុំក៏ជាអ្នករកឃើញពាងនោះ។ ណាមួយពិធីគេធំ មានន័យថាអ្វីៗដែលធ្វើកាលពីម្សិលមិនទាន់ចប់?

ខ្ញុំកេះបងឌីនឡើងមកអង្គុយពិគ្រោះ។

«បងឌីនឯងដែលឃើញគេធ្វើពិធីអីធំអ៊ីចឹងអត់? មានទូក មានពន្លា?»

បងឌីនក៏ឈ្ងោកមុខគិត។ ខ្ញុំដឹងចម្លើយស្រេចហើយថា ក្នុងចំណោមពួកយើង គ្មានអ្នកណាម្នាក់ធ្លាប់បានឃើញពិធីណាចម្លែកដល់ថ្នាក់នេះឡើយ។

«មីងម្ចាស់ផ្ទះក៏អ៊ីចឹង សួរមិននិយាយសោះ គាត់ថារវល់! ចម្លែកៗម៉េចទេស?»

ខ្ញុំរអ៊ូផង បែរខ្នងដាក់បងឌីន ហើយងាកទៅសម្លឹងពួកអ្នករៀបចំផង។

កន្ទុយភ្នែកខ្ញុំឃើញពួកអ្នកភ្លេងនៅក្រោមផ្ទះកំពុងអង្អែលក្បាលអាលិចផ្ដែខ្ញុំចុះឡើង។ វាពិតជាសុនខគួរឱ្យស្រលាញ់ ហើយមិនចេះតែព្រុសបណ្ដេញគេឯងទេ។

សម្លឹងទៅពួកអ្នកភ្លេង និងពន្លានោះជាថ្មី ខ្ញុំដឹងថា ដីនេះមានបញ្ហាពិតណាស់ មិនមែនបញ្ហាលេងផេងទេ។ ខ្ញុំលែងមាត់ ហើយថយទៅដេកគងថ្ងាសគិត។ ប្រហែលជាខ្វល់ទ្រាំមិនបានទៀត ទើបបងឌីនថយមកក្បែរអង្រឹងខ្ញុំ ហើយខ្សឹបៈ

«អញឮចាស់ៗជិតនេះគាត់លួចប្រាប់ថា ដីម្ដុំនេះជាគុកយូរយារហើយ! ក្រោយមក មានខ្មោចតាយហោងច្រើនលងសាហាវពេក បានជារដ្ឋគេរើគុកចេញទៅកន្លែងផ្សេង! គ្មានអ្នកណានៅនេះបានយូរទេ! មិនស្មានថាមានពាងឆ្អឹងទៀត ហើយយើងជាអ្នកលើក ចន្លា!»

ចិត្តខ្ញុំពាក់កណ្ដាលចង់ឆ្លើយតបនឹងបងឌីន តែខ្ជិលនិយាយអី ព្រោះឮសូរស្គរទូង ហើយភ្លេងចាប់លេង។

ពិធីគេចាប់ផ្ដើម។

អាលិចបោលមក ខ្ញុំក៏ឱបវាមើលតាអាចារ្យចាប់ពិធី។

គាត់បង្គាប់ឱ្យចាស់ៗទៅអង្គុយពីមុខទូក ហើយរៀបចំសែនអុជធូបទៀន ដោយម្ចាស់ដីអង្គុយប្រណមបែរបន់នៅមុខគេ។

ពេលធូបឆេះភុលឡើង តាអាចារ្យ និងគ្នាគាត់ចាប់ផ្ដើមស្រែកច្រៀងអមជាមួយភ្លេងនូវពាក្យចំនួនដូចជា «ចូរអ្នកនិងនាង ទៅសុខតរៀង លែងនៅវិលវល់ ចូរអ្នកស្ពាយខ្ចប់ សម្បត្តិជូនដល់ បានទៅបានយល់ ដល់ឋានខាងមុខ»

មានពាក្យច្រើនទៀតដែលខ្ញុំមិនអាចចាំបានអស់ ព្រោះយាយតាសូត្រញាប់មាត់ ហើយវែងអន្លាយ។

ដល់ចប់ពិធី គាត់បានបញ្ជាឱ្យស្រាយពន្លាយកសម្បត្តិទាំងនោះទៅបណ្ដែតចោលតាមទន្លេ ដូចកាលតាសច្ចាបណ្ដែតហឹបបុរាណចោលនោះដែរ។

លុះដល់រសៀល ក៏មានពិធីសូត្រមន្តសុំរាសីពីព្រះសង្ឃច្រើនអង្គដោយមានតាអាចារ្យជាអ្នករៀបចំ។

រួចរាល់ការអស់នេះ ខ្ញុំ និងបងឪនបានរើសម្ភារៈចាកចេញមកផ្ទះសំណាក់។

**វគ្គ**

**កំណាប់ថ្មី**

នៅថ្ងៃដដែលនោះ ថៅហ្វាយខ្ញុំបានហៅខ្ញុំទៅលើកទឹកចិត្តឱ្យបន្តការងារដោយសន្យារកកន្លែងថ្មីតាមចិត្តខ្ញុំចង់បាន។ ណាមួយចំណូល ណាមួយអាណិតគាត់ ក៏យល់ព្រមបន្តតាមគំនិតគាត់។

ដោយរាងចាលរឿងដី ខ្ញុំក៏ស្វែងរកផ្ទះល្វែងក្បែរៗផ្សារស្នាក់នៅជំនួសវិញ។ ផ្ទះថ្មីនេះស្ថិតនៅប្រមាណជា ៥០ ម៉ែត្រពីកន្លែងធ្វើការខ្ញុំប៉ុណ្ណោះ ក៏ជាសង្កាត់អ៊ូអរមានទីតាំងប្រកបអាជីវកម្មជាច្រើន។ នេះជាប្រភេទផ្ទះល្វែងដែលម្ចាស់គេសង់តខាងក្រោយទុកបន្ថែមជាផ្ទះបាយ ហើយបរិវេណផ្ទះបាយសង់បន្ថែមនេះគ្មានរៀបឥដ្ឋទេ មានតែចាក់សាបស៊ីម៉ងត៍រាបស្មើ។នៅចំតំបន់ដែលមានហាងលក់ដូរ ថ្លង់នឹងការស្រែកច្រៀងខារ៉ាអូខេ តែក៏មិនពិបាកខ្លាចបារម្ភដូចមុនដែរ។

រយៈពេលនេះ ខ្ញុំ និងភរិយារស់នៅសុខសាន្ត។

ប្រមាណបីខែក្រោយមក យប់មួយខ្ញុំបានទៅចូលរួមពិធីមង្គលរបស់អ្នកធ្វើការជាមួយគ្នាម្នាក់ នៅរួមតុជាមួយខ្ញុំ មានភ្ញៀវម្នាក់បានលើកឡើងអំពីស្ថានភាពដីចាស់ដែលខ្ញុំធ្លាប់នៅនោះថា មានចិនមួយក្រុមបានមកជួលយក ហើយបើកជាទីតាំងសំណង់ស្រាលសម្រាប់លក់កាហ្វេទំនើប។ ពួកគេរកស៊ីបានកាក់កបជាខ្លាំង មិនឃើញមានរឿងហេតុអ្វីកើតឡើងទាំងអស់។

ឮហើយ ពេញមួយយប់ខ្ញុំនឹកស្រមៃដល់ប្រវត្តិគួរឱ្យលន្លង់លន្លោចរបស់ដីនោះ។ ទោះបីជាខ្ញុំជឿថាអាគមបរព្រៃចាស់ស្រុកបានបញ្ជូនពួកគេតាមទូក និងចែកកូនផ្ទះឫស្សីឱ្យពួកគេចាកផុតពីទុក្ខសោកវិលវល់ ហើយពេលវេលាបានពន្លិចចោលប្រវត្តិសោកសង្រេងរយឆ្នាំក្នុងភូមិគ្រឹះគ្រួសារគហបតីនោះ តែរឿងរ៉ាវរបស់កូនស្រីគ្រួសារនេះនៅតែត្រូវបានខ្ញុំចងចាំមិនអាចបំភ្លេច។

ខ្ញុំដេកមិនលក់ ក៏ក្រោកមកអុជធូបឧទ្ទិសម្នាក់ឯងក្នុងចិត្តថា មិនថាប្រវត្តិពិតរបស់នារីម្ចាស់សៀវភៅឈ្មោះស្បៃរឿងនោះស្លាប់ដោយសេចក្ដីស្មោះត្រង់ចំពោះស្នេហា និងគ្មានវិធីអាចឆ្លងកាត់កំពែងវណ្ណៈកាលពីសម័យកាលនោះ ពិតត្រឹមកម្រិតណា តែខ្ញុំសង្ឃឹមថានាងបានចាប់កំណើតជាថ្មី ហើយមានជីវិតល្អប្រពៃពេញដោយសេរីភាពដូចអ្នកផងនានាក្នុងសម័យកាលដ៏ទំនើបនេះ។

ខ្ញុំគិត ហើយក៏អុជធូបចោល ព្រមទាំងសូត្រធម៌សុំសុខមិនឱ្យមានសុបិនអ្វីកើតឡើង រួចទើបចូលទៅប្រះលង់លក់ទៅក្បែរប្រពន្ធកូន។

ពេញមួយយប់ ខ្ញុំពិតជាមិនបានជួបសុបិន ឬទទួលអារម្មណ៍ដឹងហេតុភេទអ្វីគួរឱ្យកត់សម្គាល់ទាំងអស់ គឺគេងលក់ស្រួលស្លុងតែម្តង ប៉ុន្តែនៅពេលជិតភ្លឺ សំឡេងមនុស្សស្រីបាននិយាយច្បាស់ៗនៅជិតត្រចៀកខ្ញុំថា៖

«ខ្លួនឯងបានជួយយើង យើងមានរបស់ជាការតបស្នងសងគុណ! នៅក្រោមផ្ទះដែលខ្លួនកំពុងនៅនេះ មានវត្ថុមានតម្លៃដែលគ្មានម្ចាស់ទេ ហើយខ្លួនឯងនឹងបានទទួលវាដោយសុខសប្បាយ ចូរទៅជីកយកនៅក្រោមដែលប្រពន្ធខ្លួនបានដាក់បាវអង្ករនោះ!»

ខ្ញុំឮហើយ ភ្ញាក់ដឹងខ្លួនស្វាងថៃស ចំពេលមេឃបើកថ្ងៃស្រឡះឆ្វង់។

សុបិនថ្មើរណោះ ច្រើនតែជាប្រផ្នូលអំពីការពិត នេះបើតាមការចំណាំរបស់ខ្មែរយើង។

តែខ្ញុំមិនបានជ្រើមជ្រួលនឹងរឿងអស់នេះឡើយ។

ខ្ញុំមិននិយាយរឿងនេះប្រាប់អ្នកណាសូម្បីតែភរិយា ឬម្តាយក្មេកដែលមកស្នាក់នៅជាមួយគ្នា។ ប៉ុន្តែរាល់ពេលចេញចូលក្នុងផ្ទះ ខ្ញុំតែងលួចដៀងភ្នែកពិនិត្យមើលកន្លែងដែលប្រពន្ធខ្ញុំដាក់បាវអង្ករនោះជានិច្ច។

ប៉ុន្មានថ្ងៃក្រោយមក ពូម្ចាស់ផ្ទះមកទទួលលុយដូចសព្វដង។ គាត់ឈ្មោះធី អាយុប្រមាណ៦០ ប្លាយតែគាត់រួសរាយនិយាយលេងច្រើនដូចជាយុវវ័យ។ ដោយបានឱកាស គាត់អង្គុយនិយាយប្រាជ្ញយូរ និងដោយគ្មានអ្នកណានៅផ្ទះ ខ្ញុំក៏ឆ្លៀតឱកាសជជែកជាមួយគាត់រឿងសុបិនផ្ទាល់ត្រចៀករឿងកំណប់ក្រោមបាវអង្ករនោះ។

ឮហើយកាលណា គាត់សំកាំងស្តាប់ខ្ញុំនិយាយពីដើមដល់ចប់។ ចុងក្រោយ ខ្ញុំពន្យល់គាត់ថា ខ្ញុំមិនដឹងសុបិននោះមានការពិតកម្រិតណាទេ ប៉ុន្តែទោះបីជាមានអ្វីក៏ដោយ ខ្ញុំពុំមែនជាម្ចាស់ផ្ទះ ខ្ញុំមិនមានចិត្តអ្វីលើរបស់អស់នោះ គ្រាន់តែខ្ញុំនៅមិនសុខក្នុងចិត្តសោះ ពេលមិនបាននិយាយរឿងនេះប្រាប់គាត់។

ចុងក្រោយ គាត់សម្រេចចិត្តថានឹងរកឱកាសស្វាត់គាស់មើលជាមួយគ្នា។

ពេលនោះយើងរកបានឱកាសមួយមិនឱ្យមានអ្នកណានៅផ្ទះទេ។ ខ្ញុំក៏ជីកជាមួយគាត់ពីរនាក់តទល់។ ដំបូង យើងគិតថា ការងារនេះនឹងហត់នឿយខ្លាំង ក៏ថែមទាំងមិនដឹងច្បាស់ថាសុបិននោះមាន

ការពិតកម្រិតណាទៀត គ្រាន់តែដើម្បីឱ្យអស់ចិត្តប៉ុណ្ណោះ តែជីករូងមិនទាន់បានបែកញើស ស្រួលបួលផង យើងពិតជារកឃើញកញ្ចប់ប្លាស្ទិកដែលខ្ចប់គ្រឿងអលង្ការមាសក្រហមឆ្អិន និងត្បូង មានតម្លៃធ្ងន់រាប់គីឡូ។

ក្រោយពីភ្ញាក់ផ្អើលនិយាយមិនចេញចំពោះកំណប់នោះ ម្ចាស់ផ្ទះបានស្ម័គ្រចិត្តចែករំលែកមួយ ចំណែកយ៉ាងក្រៃលមកឱ្យខ្ញុំ។ ខ្ញុំទទួលយក ហើយរង់ចាំអ្នកផ្ទះមកជុំគ្នា ក៏ពិគ្រោះថានឹងគិតយ៉ាង ណាចំពោះលាភនោះ?

ម្ដាយក្មេកខ្ញុំបានឱ្យយករបស់នេះទៅទូលសួរព្រះចៅអធិការវត្តឯស្រុកខាងភរិយាខ្ញុំ។ ពេលនោះ លោកឆ្លើយថាខ្ញុំមានវាសនាប្រើវាបាន ដោយសារតែរបស់នេះគ្មានម្ចាស់ ហើយម្ចាស់ផ្ទះក៏គេបាន យល់ព្រមបែងចែកឱ្យដោយមិនទោមនស្ស ដូច្នេះវាក្លាយជាទ្រព្យសម្បត្តិត្រជាក់ត្រជំរបស់គ្រួសារខ្ញុំ ចាប់ពីពេលនោះមក។

ចាប់ពីពេលនោះមក ពួកខ្ញុំបានរស់នៅប្រកបរបរចិញ្ចឹមជីវិតដោយសុខដុមរមនា ហើយរាប់អាន ម្ចាស់ផ្ទះនោះយ៉ាងស្និទ្ធស្នាលតរៀងមក ទោះបីពួកខ្ញុំឈប់ជួលទីនោះដើម្បីរស់នៅទៀតក៏ដោយ។

**មតិអ្នកនិពន្ធ**

ខ្មែរមានជំនឿច្រើនណាស់ជុំវិញអាគមបរព្រៃដែលជាអាគមដ៏ស័ក្ដិសិទ្ធមានអាយុកាលពាន់ឆ្នាំមកហើ យ។ គេប្រើសម្រាប់អញ្ជើញអ្នកទំនៅលើដើមព្រឹក្សានានាឱ្យចាកចេញ យកកន្លែងធ្វើកិច្ចផ្សេងៗ ក្រោយមកក៏មានតំបន់ខ្លះ បានយកអាគមបរព្រៃនេះសម្រាប់បណ្ដេញបញ្ជូនវិញ្ញាណវិលវល់ ទាំងឡាយឱ្យទៅកាន់ទីព្រៃជ្រៅ លែងនៅវិលវល់នឹងភូមិដ្ឋាន ប៉ុន្តែឈ្មោះនៃពិធីការតែងប្រែប្រួល ទៅតាមតំបន់នានា ដូចជាខ្លះហៅថា ពិធីនាងយាង នាងចរ ពិធីបរព្រៃ និងពិធីសែនបណ្ដែត។ល។ ដូច្នេះហើយ យើងឃើញជាតំណមក ចាស់ៗចំណាំហាមកូនចៅកុំឱ្យស្រង់យករបស់របរណាដែល ឃើញបណ្ដែតទឹកមក ព្រោះថាវាអាចជាគ្រឿងបណ្ដេញឧបទ្រព្យនៃពិធីបរព្រៃបណ្ដេញវិញ្ញាណ។

ដូចក្នុងរឿងគាថាបុរាណដែរ ការមិនមានចិត្តលោភបំពានជីកកាយកាប់គាស់ស្វែងរកសម្បត្តិទ្រព្យ ដែលពុំបានថាឱ្យមកខ្លួនដោយម្ចាស់គេ នឹងនាំមកនូវសេចក្ដីសុខដល់អាត្មាក៏ដូចជាគ្រួសារទាំងមូ ល៕